# កម្មវិធីអ្នកដឹកនាំវ័យក្មេងកម្ពុជា-ឡាវ

## Cambodia Laos Young Leaders Programme - FAQs

### តើខ្ញុំនឹងទទួលបានការណែនាំអំពីការរស់នៅក្នុងប្រទេសAotearoaនូវែលសេឡង់ និងអ្វីដែលត្រូវរំពឹងទុកជាមុនដែរឬទេ?

**Will I get guidance on living in Aotearoa New Zealand and what to expect?**

- បាទ/ចាស ! ការណែនាំលម្អិតត្រូវបានផ្តល់ជូនដល់សិក្ខាកាមទាំងអស់អំពីបញ្ហាសុខភាព សុវត្ថិភាព សុខមាលភាព និងការអនុវត្តជាក់ស្តែង ។ សិក្ខាកាមទាំងអស់ត្រូវបានផ្តល់ជូនសៀវភៅណែមួយមុនពេលចេញដំណើរ និងសៀវភៅណែនាំលម្អិតបន្ថែមទៀតនៅពេលមកដល់ក្រុង Auckland ។
- Yes! Detailed guidance is provided to all participants on health, safety, wellbeing and practical issues. Participants are provided with a pre-departure handbook, and a more detailed orientation handbook on arrival in Auckland.

### តើខ្ញុំនឹងទទួលបានជំនួយក្នុងការធ្វើដំណើរទៅប្រទេសAotearoaនូវែលសេឡង់ ឬទេ?

**Will I get help with travel to Aotearoa New Zealand?**

- បាទ/ចាស ! រាល់ការចំណាយលើការធ្វើដំណើរទាំងអស់ត្រូវបានបង់ដោយ UnionAID
- Yes! All travel costs are paid by UnionAID
- អង្គការដៃគូក្នុងស្រុករបស់យើងក្នុងប្រទេសកម្ពុជា/ឡាវ នឹងរៀបចំការធ្វើដំណើរក្នុងស្រុករបស់លោកអ្នក ។
- Our local partner organisations in Cambodia / Laos will arrange your domestic travel
- ទិដ្ឋាការ(វីសា)ត្រូវបានរៀបចំ និងបង់ប្រាក់ដោយ UnionAID
- Visas are arranged and paid for by UnionAID
- លោកអ្នកនឹងធ្វើដំណើរទៅ Aotearoa New Zealand ជាក្រុម ដូច្នេះលោកអ្នកនឹងមិនមែននៅតែម្នាក់ឯងទេ ។
- You will travel to Aotearoa New Zealand as a group, so you will not be alone

### តើការរស់នៅក្នុងផ្ទះគីវីនឹងទៅជាយ៉ាងណាដែរ? តើខ្ញុំនឹងរស់នៅទីកន្លែងណា?

**What will it be like living in a Kiwi home? Where will I live?**

- សិក្ខាកាមទាំងអស់ស្នាក់នៅជាមួយឪពុកម្តាយម្ចាស់ផ្ទះ ឬគ្រួសារម្ចាស់ផ្ទះ ។ គ្រួសារទទួលសិក្ខាកាមស្នាក់នៅ ត្រូវបានជ្រើសរើសយ៉ាងប្រុងប្រយ័ត្នដោយ UnionAID ។ ភាគច្រើនធ្លាប់ធ្វើជាម្ចាស់ផ្ទះ នៃអ្នកដឹកនាំវ័យក្មេងអន្តរជាតិ។ លោកអ្នកនឹងមានបន្ទប់ផ្ទាល់ខ្លួនរបស់លោកអ្នក ដែលជាកន្លែងសុវត្ថិភាពរបស់លោកអ្នកសម្រាប់សម្រាក និងលំហែកាយ។
- Participants stay with a local host parent or host family. Hosts have been carefully selected by UnionAID. Most have previously hosted international Young Leaders. You will have your own private room which is your safe space to rest and relax.
- ម្ចាស់ផ្ទះរបស់អ្នកនឹងដឹងអំពីតម្រូវការរបបអាហាររបស់អ្នក ហើយនឹងផ្តល់អាហារ២ពេលក្នុងមួយថ្ងៃនៅថ្ងៃធ្វើការ និងអាហារ៣ពេលក្នុងមួយថ្ងៃនៅថ្ងៃចុងសប្តាហ៍ ។ លោកអ្នកអាចប្រើប្រាស់ផ្ទះបាយបាន ដូច្នេះលោកអ្នកអាចចម្អិនម្ហូបអាហារដែលលោកអ្នកចូលចិត្តបានផងដែរ ។ ម្ចាស់ផ្ទះមានម៉ាស៊ីនបោកគក់ខោអាវសម្រាប់លោកអ្នក ហើយម្ចាស់ផ្ទះនឹងណែនាំអ្នកពីរបៀបប្រើប្រាស់ឧបករណ៍ទាំងអស់។ ដូចគ្នានឹងផ្ទះផ្សេងៗទៀតដែរ ដែលនាំមកនូវការយកចិត្តទុកដាក់ និងសេចក្តីស្រឡាញ់ ។
- Your host will be aware of your dietary needs and will provide 2 meals a day on weekdays, and 3 meals a day on weekends. You will be able to use the kitchen, so you can also cook your favourite foods.

There will be a washing machine for your laundry and your host will guide you on how to use all utilities. Just like any other home, it all comes with care and love.

- តាមរយៈការរស់នៅជាមួយគ្រួសារម្ចាស់ផ្ទះ លោកអ្នកនឹងមានឱកាសស្វែងយល់អំពីវប្បធម៌គីវី និងជីវិតនៅនូវែលសេឡង់នៅខាងក្រៅបរិយាកាសសិក្សា និងបរិវេណសាលា។ លោកអ្នកនឹងចំណាយពេលកំសាន្តជាមួយគ្រួសារម្ចាស់ផ្ទះរបស់លោកអ្នក ដែលរួមមាន កីឡា សកម្មភាពក្រៅផ្ទះ ឬដំណើរកម្សាន្តទៅកាន់កន្លែងដែលចាប់អារម្មណ៍។ ឪពុកម្តាយម្ចាស់ផ្ទះមានការគាំទ្រយ៉ាងខ្លាំងចំពោះកម្មវិធីនេះ ហើយជារឿយៗត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសកម្មភាពជាក្រុម ។
- By living with a host family, you will have a chance to learn about Kiwi culture and New Zealand life outside the academic and campus environment. You will spend recreational time with your host family, which may include sports, outdoor activities or trips to places of interest. Host parents are very supportive of the programme and are often invited to join group activities.





## ការធ្វើដំណើរនៅក្នុងAuckland

**Transport in Auckland.**

- Auckland ត្រូវបានលាតសន្ធឹងនៅលើតំបន់ដ៏ធំមួយ ដូច្នេះការធ្វើដំណើរចូលទៅក្នុងទីក្រុងអាចចំណាយពេលមួយម៉ោង ឬយូរជាងនេះ ប៉ុន្តែសេវាដឹកជញ្ជូនសាធារណៈប្រព្រឹត្តទៅបានយ៉ាងល្អ ។ អ្នកនឹងទទួលបានកាតបង់ប្រាក់ដែលមានឈ្មោះថា 'AT Hop' ដែលប្រើនៅលើរថយន្តក្រុង រថភ្លើង និងសាឡាងទាំងអស់នៅក្នុងក្រុង Auckland។
- Auckland is spread over a large area, so commuting into the city can take one hour or longer, but there is good public transport. You will receive a payment card called 'AT Hop' that is used on all Auckland buses, trains and ferries.

## ខ្ញុំមានចំណង់ចំណូលចិត្ត លេងកីឡា ឬចង់ចូលរួមសង្គមនៅ Auckland។ តើខ្ញុំអាចធ្វើវាដោយរបៀបណា ?

**I have a hobby, play a sport, or want to socialise in Auckland. How can I do that?**

- វគ្គសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅនូវែលសេឡង់ នឹងមានទីតាំងនៅសាកលវិទ្យាល័យបច្ចេកវិទ្យា Auckland (AUT) ។ ក្នុងនោះមានក្រុម និងក្លឹបចំណង់ចំណូលចិត្តជាច្រើនដែលមាននៅសាកលវិទ្យាល័យបច្ចេកវិទ្យា និងនៅក្នុងសហគមន៍ធំទូលាយ។ សាលកីឡា ឧទ្យាន បណ្ណាល័យ និងសារមន្ទីរមានយ៉ាងទូលំទូលាយនៅក្រុង Auckland ។ មានព្រឹត្តិការណ៍សាធារណៈជាច្រើនដែលបានប្រារព្ធឡើងដោយសេរីនៅក្នុងទីក្រុង។
- The Sustainable Development Course in NZ will be based at the Auckland University of Technology (AUT). There are many hobby groups and clubs available at AUT and in the wider community. Sports halls, parks, libraries, and museums are widely available in Auckland. There are many free, public events held in the city.
- សិក្ខាកាមមានសិទ្ធិចូលទៅកាន់មជ្ឈមណ្ឌលកម្សាន្ត AUT ។ សមាគមនិស្សិត AUT (AUTSA) គឺមានសមកម្មភាពផុលផុសខ្លាំងណាស់ ហើយមានក្លឹបនិស្សិត និងសកម្មភាពជាច្រើនទៀតដែលលោកអ្នកអាចចូលរួមបាន ។
- Participants have access to the AUT recreation centre. The AUT Student Association (AUTSA) is very active and there are many student clubs and activities you can join.

  

## តើខ្ញុំអាចបរិភោគអាហារអាស៊ីបានទេ?

**Will I be able to eat Asian food?**

- ម្ហូបអាហារគឺខុសគ្នាខ្លាំងណាស់នៅ Aotearoa New Zealand ។ ទោះជាយ៉ាងណា ម្ហូបអាហារអាស៊ីអាចរកទិញបាននៅផ្សារទំនើបអាស៊ី ។
- Food is very different in Aotearoa New Zealand. However Asian food is readily available at Asian supermarkets.
- មានភោជនីយដ្ឋានថៃ/ឡាវ និងខ្មែរនៅ Auckland
- There are Thai/Lao and Khmer restaurants in Auckland

## ចុះប្រសិនបើខ្ញុំឈឺពេលស្នាក់នៅ Aotearoa New Zealand ឬតស៊ូជាមួយនិងសុខភាពផ្លូវចិត្តរបស់ខ្ញុំ ?

**What if I get sick while in Aotearoa New Zealand or struggle with my mental health?**

- UnionAID ផ្តល់ការធានារ៉ាប់រងលើការធ្វើដំណើរ និងសុខភាពសម្រាប់សិក្ខាកាមទាំងអស់ ដែលនឹងទទួលរ៉ាប់រងការចំណាយលើសុខភាពភាគច្រើន ។ AUT មានសេវាព្យាបាលដោយឥតគិតថ្លៃសម្រាប់សិស្សនិស្សិត។
- UnionAID provides travel and health insurance for all participants, which will cover most health costs. AUT has free medical services for students.
- AUT ផ្តល់ដំបូន្មាន និងការគាំទ្រជាក់លាក់សម្រាប់និស្សិតអន្តរជាតិ ។ បុគ្គលិករបស់ UnionAID ក៏មានបទពិសោធន៍ក្នុងការជួយដល់និស្សិតអន្តរជាតិ និងអាចជួយណែនាំលោកអ្នកទៅកាន់សេវាកម្មណាមួយដែលលោកអ្នកអាចត្រូវការ។
- AUT provides specific advice and support for international students. UnionAID staff are also experienced in supporting international students and can help to direct you to any services you may need.
- លោកអ្នកអាចចូលប្រើប្រាស់សេវាប្រឹក្សានៃ AUT នៅចំពោះមុខ ឬតាមរយៈទូរស័ព្ទ
- You can access AUT counselling either face to face or over the phone.

## ខ្ញុំមានពិការភាព ។ តើខ្ញុំនឹងត្រូវទទួលបានការគាំទ្រល្អឬទេ ?

**I have a disability. Will I be well supported?**

- បាទ/ចាស ! យើងនឹងធ្វើការជាមួយលោកអ្នកមុនពេលអ្នកមកដល់ ដើម្បីធានាថាយើងមានជំនួយបន្ថែមប្រសិនបើចាំបាច់។ យើងប្តេជ្ញាធានាថា អ្នកដឹកនាំវ័យក្មេងទាំងអស់អាចចូលរួមយ៉ាងពេញលេញនៅក្នុងកម្មវិធីនេះ។
- Yes! We will work with you before you arrive to ensure we have additional support if required. We are committed to ensuring that all young leaders can fully participate in the programme.
- AUT ផ្តល់អ្នកឯកទេសលើសេវាកម្មគាំទ្រពិការភាព
- AUT offers a specialist disability support service

## តើខ្ញុំអាចរក្សាទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិដោយរបៀបណា ?

**How will I be able to stay in touch with family and friends?**

- អ្នកនឹងទទួលបានស៊ីមកាត NZ និងប្រាក់ឧបត្ថម្ភទូរស័ព្ទ
- You will receive a NZ Sim card and a phone allowance
- មាន WIFI ឥតគិតថ្លៃនៅ AUT ហើយម្ចាស់ផ្ទះទាំងអស់មាន WIFI នៅក្នុងផ្ទះរបស់ពួកគេ ។

- There is free WIFI at AUT, and all hosts have WIFI in their homes
- ទីកន្លែងសាធារណៈជាច្រើននៅ Auckland មាន WIFI ឥតគិតថ្លៃ (បណ្ណាល័យ ហាងកាហ្វេ។ល។)
- Many public places in Auckland have free WIFI (libraries, cafes etc.)

## តើខ្ញុំអាចប្រតិបត្តិគោរពសាសនារបស់ខ្ញុំបានឬទេ?

**Can I practise my religion?**

- បាទ/ចាស ! សេរីភាពខាងសាសនា និងការអត់ឱនខាងសាសនា គឺជាសិទ្ធិជាមូលដ្ឋាននៅក្នុងប្រទេសនូវែលសេឡង់
- Yes! Freedom of religion and religious tolerance is a basic right in New Zealand
- មានវត្តអារាមព្រះពុទ្ធសាសនា ព្រះវិហារឥស្លាម និងព្រះវិហារគ្រីស្តនៅ Auckland
- There are Buddhist temples, mosques and churches in Auckland
- មានបន្ទប់ពហុអធិស្ឋានឧទ្ទិសបួងសួងលើជំនឿសាសនានៅក្នុងបរិវេណសាលានៅ AUT
- There is a multi-faith prayer room on campus at AUT

## ខ្ញុំជា LGBTQI+ (ស្ត្រីស្រឡាញ់ភេទដូចគ្នា, ខ្ទើយ, អ្នកស្រឡាញ់ភេទដូចគ្នា, អ្នកប្តូរភេទ...) តើខ្ញុំនឹងភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ឥន្ទធនូនៅ Auckland យ៉ាងដូចម្តេច?

**I’m LGBTQI+, how will I connect with the rainbow community in Auckland?**

- AUT មានក្រុមគាំទ្រឥន្ទធនូ ដែលអាចភ្ជាប់ទំនាក់ទំនងជាមួយអ្នក មុនពេលអ្នកទៅដល់នូវែលសេឡង់ ។ អាគារទាំងអស់មានបន្ទប់ទឹកសម្រាប់គ្រប់ភេទទាំងអស់ ហើយមានកន្លែងសុវត្ថិភាពឥន្ទធនូ (ប្លុក WB) នៅលើបរិវេណសាលាធំ។
- AUT have a rainbow support team who can connect with you before you arrive in New Zealand. All buildings have all-gender bathrooms and there is a rainbow safe space (WB block) on the main campus.
- មានអង្គការល្អៗជាច្រើននៅ Auckland ដែលគាំទ្រសហគមន៍ឥន្ទធនូ ដូចជា Rainbow Youth ជាដើម ។ យើងទៅជួបអង្គការទាំងនេះមួយចំនួនដែលជាផ្នែកមួយនៃកម្មវិធីក្រុមរបស់យើង។
- There are several excellent organisations in Auckland that support the rainbow community, such as Rainbow Youth. We visit some of these organisations as part of our group programme.

## តើខ្ញុំនឹងមានអារម្មណ៍សុវត្ថិភាពឬទេ?

**Will I feel safe?**

- AUT មានសន្តិសុខ ២៤/៧ និងលើកទឹកចិត្តសិស្សឱ្យទាញយកកម្មវិធី AUT Safe
- AUT has 24/7 security and encourage students to download the AUT Safe app.
- បុគ្គលិក UnionAID និងគ្រួសារម្ចាស់ផ្ទះអាចទាក់ទងបានគ្រប់ពេលក្នុងគ្រាមានអាសន្ន
- UnionAID staff and host families are contactable anytime in an emergency
- សិក្ខាកាមទាំងអស់ទទួលបានព័ត៌មានលម្អិតអំពីសុវត្ថិភាពផ្ទាល់ខ្លួនក្នុងអំឡុងពេលសប្តាហ៍ណែនាំតម្រង់ទិស
- Participants receive detailed information on personal safety during orientation week